QR Translator® ភាសាខ្មែរ

ព័ត៌មានខាងក្រោមនេះគឺជាការបកប្រែពីភាសាជប៉ុន។

ប្រកាសអាសន្នកម្រិត 4

# ចាប់ពីថ្ងៃទី20 ខែឧសភា ឆ្នាំ2021

# ធ្វើការភៀសខ្លួន ទៅតាមការតម្រូវឱ្យភៀសខ្លួន

# ការណែនាំឱ្យភៀសខ្លួន នឹងមិនផ្សព្វផ្សាយជូនទៀតទេ

| ប្រកាសអាសន្នកម្រិត | | ព័ត៌មានថ្មីៗអំពីការភៀសខ្លួន | | ប្រព័ន្ធព័ត៌មានអំពីការភៀសខ្លួនពីមុន |
|---|---|---|---|---|
| 5 |  ហេតុការណ៍គ្រោះមហន្តរាយ/ គ្រោះមហន្តរាយ ដែលនឹងកើតឡើង | វិធានការសុវត្ថិភាពក្នុងគ្រាអាសន្ន ※1 | ↖ | ព័ត៌មានអំពីការកើតឡើងនៃគ្រោះមហន្តរាយ (នឹងចេញប្រកាសនៅពេលដែលហេតុការណ៍ត្រូវបានបញ្ជាក់ថាកើតមានមែន) |
| ~~~<សូមធ្វើការភៀសខ្លួន ទៅតាមការប្រកាសអាសន្ន កម្រិតទី4!>~~~ | | | | |
| 4 |  ហានិភ័យគ្រោះ មហន្តរាយខ្ពស់ | ការតម្រូវឱ្យភៀសខ្លួន ※2 | ← | ·ការតម្រូវឱ្យភៀសខ្លួន(បន្ទាន់) ·ការណែនាំឱ្យភៀសខ្លួន |
| 3 |  ហានិភ័យ នៃគ្រោះមហន្តរាយ | ការភៀសខ្លួនមនុស្សចាស់។ល។ ※3 | ← | ការត្រៀមភៀសខ្លួន· ការចាប់ផ្តើមភៀសខ្លួនចំពោះមនុស្សចាស់ជាដើម |
| 2 |  អាកាសធាតុកាន់តែដុនដាបទៅៗ | សេចក្តីប្រកាសព័ត៌មានអំពីភ្លៀង ទឹកជំនន់ ឬព្យុះធ្ងន់ធ្ងរ (ទីភ្នាក់ការឧតុនិយមប្រទេសជប៉ុន) | | សេចក្តីប្រកាសព័ត៌មានអំពីភ្លៀង ទឹកជំនន់ ឬព្យុះធ្ងន់ធ្ងរ (ទីភ្នាក់ការឧតុនិយមប្រទេសជប៉ុន) |
| 1 |  ហានិភ័យនៃការដុនដាបរបស់អាកាសធាតុ | លទ្ធភាពនៃការព្រមាន (ទីភ្នាក់ការឧតុនិយមប្រទេសជប៉ុន) | | លទ្ធភាពនៃការព្រមាន (ទីភ្នាក់ការឧតុនិយមប្រទេសជប៉ុន) |

ចំណាំទី 1៖ ការប្រកាសអាសន្នកម្រិតទី 5 នឹងមិនមានចេញប្រកាសរហូតទេ ពីព្រោះ ឧទាហរណ៍អាជ្ញាធរក្រុងមិនអាចស្វែងយល់អំពីស្ថានភាពរបស់គ្រោះមហន្តរាយបានច្បាស់លាស់។

ចំណាំទី 2៖ ការតម្រូវឱ្យភៀសខ្លួននឹងប្រកាសនៅក្នុងពេលតែមួយជាមួយនឹងការប្រកាសណែនាំឱ្យភៀសខ្លួននៅក្នុងប្រព័ន្ធពីមុន

ចំណាំទី 3៖ ការប្រកាសអាសន្នកម្រិតទី 3 គឺជាពេលវេលាដែលប្រជាជនក្រៅពីមនុស្សចាស់ ជាដើម ត្រូវចាប់ផ្តើមសម្រួលឥរិយាបថ ឬត្រៀមលក្ខណៈសម្រាប់ការភៀសខ្លួនតាមការចាំបាច់ ឬធ្វើការភៀសខ្លួនដោយខ្លួនឯងប្រសិនបើខ្លួនគិតថាអាចមានគ្រោះថ្នាក់ដល់អាយុជីវិតរបស់ខ្លួន។

---

**ការប្រកាសអាសន្នកម្រិតទី 5 មានន័យថា ជាស្ថានភាពគ្រោះថ្នាក់ ដល់អាយុជីវិតដែលអ្នកមិនអាចធ្វើការភៀសខ្លួន ដោយសុវត្ថិភាពបានឡើយ។**
**សូមកុំរង់ចាំឱ្យមានការប្រកាសវិធានការសុវត្ថិភាពក្នុងគ្រាអាសន្ន កម្រិតទី 5 ឱ្យសោះ**

**ការណែនាំឱ្យភៀសខ្លួន នឹងមិនផ្សព្វផ្សាយជូនទៀតទេ។**
**ចាប់ពីពេលនេះតទៅ**
**ម្ចាស់លំនៅដ្ឋានទាំងអស់ ត្រូវភៀសខ្លួនចេញពីទីតាំងគ្រោះថ្នាក់នៅពេលដែលមានការប្រកាសអាសន្នកម្រិតទី 4 ការតម្រូវឱ្យភៀសខ្លួន**

**មនុស្សចាស់ ឬជនមានពិការភាព**
**ដែលអាចនឹងត្រូវការពេលច្រើនក្នុងការភៀសខ្លួន**
**គួរធ្វើការភៀសខ្លួនពីទីតាំងគ្រោះថ្នាក់នៅពេលដែលមានការប្រកាសអាសន្នកម្រិតទី 3 ការភៀសខ្លួនមនុស្សចាស់។ល។**